សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)
Cambodian Water Supply Association (C.W.A)

# កំណត់ហេតុ
# សន្និបាតលើកទី១១ ប្រចាំឆ្នាំ២០២២
# សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

## ១. សេចក្តីផ្តើម

ថ្ងៃសុក្រ ១២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ៨:០០ព្រឹក សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក) បានរៀបចំសន្និបាតប្រចាំឆ្នាំលើកទី១១ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧវបន) និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងឧវបន និង **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។

## ២. គោលបំណង

សមាគមបានរៀបចំសន្និបាតលើកទី១១ ប្រចាំឆ្នាំ២០២២ ក្នុងគោលបំណងៈ

- បង្កើនទំនាក់ទំនងរវាងសមាជិកសមាគមឱ្យកាន់តែប្រសើរឡើង និងចែករំលែកបច្ចេកវិទ្យាថ្មីៗ
- អបអរសាទរសមិទ្ធិផលរបស់សមាគមក្នុងឆ្នាំ២០២២ និងរៀបចំផែនការការងារ សម្រាប់ឆ្នាំ ២០២៣
- ធ្វើបច្ចុប្បន្នភាពសមាជិកភាព និងពិភាក្សាអំពី បញ្ហាប្រឈម ដំណោះស្រាយ និងការងារផ្សេងៗ។

អង្គសន្និបាតមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួងឧវបន តំណាងក្រសួងអភិវឌ្ឍន៍ជនបទ តំណាងស្ថានទូតចក្រភពអង់គ្លេស ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការប្រតិបត្តិ បុគ្គលិក ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ក្រុមហ៊ុនផ្គត់ផ្គង់ផលិតផល និងសេវាកម្មក្នុងវិស័យទឹកស្អាតដែលជាសមាជិកសមាគម ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សរុបចំនួន ៣០៦នាក់ (ស្រី ៦៥នាក់)។ ជាងនេះទៅទៀត ក៏មានក្រុមហ៊ុនចំនួន ១៣ បានតាំងបង្ហាញផលិតផល និងសេវាកម្មពាក់ព័ន្ធនឹងវិស័យទឹកស្អាត។

## ៣. របៀបវារៈ

១. កិច្ចស្វាគមន៍ ដោយ **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម

២. សុន្ទរកថាបើក អង្គសន្និបាតលើកទី១១ប្រចាំឆ្នាំ២០២២ ដោយ **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧវបន) និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួង ឧវបន។

៣. បទបង្ហាញពីសមិទ្ធិផលការងារក្នុងឆ្នាំ២០២២ និងផែនការប្រចាំឆ្នាំ២០២៣
៤. ការផ្តល់វត្ថុអនុស្សាវរីយ៍ជូនគណៈអធិបតី និងក្រុមប្រឹក្សាភិបាល
៥. បទបង្ហាញពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន ដោយតំណាងក្រុមហ៊ុនទាំង១៣
៦. បច្ចុប្បន្នភាពអំពី«កាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» ដោយ លោក ប៊ុនហេង REACHS & Partners
៧. ទស្សនាការតាំងពិព័រណ៍បច្ចេកវិទ្យា និងផលិតផលទឹកស្អាត
៨. ការចែករំលែកបទពិសោធន៍ពីទស្សនកិច្ចសិក្សានៅប្រទេសម៉ាឡេស៊ី និងប្រទេសជប៉ុន ដោយ លោកស្រី ព្រាប បូទុមសិលា និង លោកស្រី ស៊ឹម សៀមនី
៩. សំឡេងសមាជិកភាព និងដំណោះស្រាយ
១០.បូកសរុប និងបិទអង្គសន្និបាត

អង្គសន្និបាតបានរៀបចំឡើងដោយអនុវត្តតាមវិធានការណ៍ការពារ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាល។

# ៤. លទ្ធផលអង្គសន្និបាត

## ៤.១ កិច្ចស្វាគមន៍ និងសុន្ទរកថាបើកកម្មវិធីអង្គសន្និបាត

ក. មតិស្វាគមន៍សន្និបាតលើកទី១១

ជាកិច្ចចាប់ផ្តើម **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម បានថ្លែងសុន្ទរកថាស្វាគមន៍ដល់អង្គសន្និបាត និងថ្លែងអំណរគុណដល់ក្រសួងឧស្សាហកម្ម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រុមប្រឹក្សាភិបាល បុគ្គលិក សមាជិកសមាជិកា អ្នកឧបត្ថម្ភកម្មវិធី អង្គការដៃគូទាំងអស់ដែលបានចូលរួមក្នុងសន្និបាតលើកទី១១។ **លោក ឡេង ខៀវ** ក៏បានបង្ហាញពីការចូលរួមរបស់សមាគម និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ដើម្បីសម្រេចបាននូវគោលនយោបាយរបស់រាជរដ្ឋាភិបាលនៅត្រឹមឆ្នាំ២០២៥«ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទីប្រជុំជនទទួលបានទឹកស្អាតប្រើប្រាស់១00% ដែលក្នុងនោះ ៩០%ពីការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ និង១០% ពីប្រភពផ្សេង» និងនៅត្រឹមឆ្នាំ ២០៣០ សម្រេចនូវការទទួលបានសាកលកម្ម និងសមធម៌នូវទឹកបរិភោគដែលមានសុវត្ថិភាព និងថ្លៃសមរម្យ សម្រាប់ប្រជាជនទាំងអស់។ លោកក៏បានបង្ហាញពីផែនការយុទ្ធសាស្ត្ររបស់សមាគមចំនួន៣ ដូចខាងក្រោម៖

- ការពារ និងពង្រឹងសមត្ថភាពសមាជិករបស់ខ្លួន
- ធ្វើឱ្យមាននិរន្តរភាពហិរញ្ញវត្ថុសមាគម
- លើកទឹកចិត្តសមាជិកក្នុងការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋដើម្បីចូលរួមចំណែកក្នុងការសម្រេចបាននូវលទ្ធភាពប្រើប្រាស់ជាសកលត្រឹមឆ្នាំ២០៣០។

ក្រៅពីនេះសមាគម ក៏បានជំរុញលើការការពារនូវប្រភពទឹក ការផ្គត់ផ្គង់ និងការពង្រឹងនូវគុណភាពទឹករបស់ប្រតិបត្តិករ។ ជាងនេះទៅទៀតសមាគមក៏បានស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យពិចារណាលើចំណុចដូចខាងក្រោម៖

- សុំឱ្យមានសំណងពីផលប៉ះពាល់ពេលខូចខាតបំពង់ទឹកស្អាត

❖ ការលើកលែងពន្ធលើប្រាក់ចំណូល
❖ ការលើកលែងពន្ធអាករលើតម្លៃបន្ថែម(VAT) លើថ្លៃតំណា
❖ សុំឱ្យមានកម្ចីដែលមានការប្រាក់ទាប និងងាយស្រួលសម្រាប់វិស័យទឹកស្អាត។

លោកប្រធានក៏បានស្នើឱ្យសមាជិកទាំងអស់ចែករំលែកបទពិសោធន៍ និងការរៀនសូត្រទៅវិញទៅមក និងយកវេទិកានេះសម្រាប់លើកឡើងពីក្តីកង្វល់ បញ្ហាប្រឈម មកពិភាក្សាគ្នាដើម្បីរកដំណោះស្រាយរួមមួយទាក់ទងទៅនឹងវិស័យទឹកស្អាត។

ខ. សុន្ទរកថា បើកកម្មវិធីសន្និបាតលើកទី១១

ជាកិច្ចបន្ត **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងឧស្សាហកម្ម... ក្រសួងឧវបន បានអញ្ជើញថ្លែងសុន្ទរកថាបើកអង្គសន្និបាត។ **ឯកឧត្តម** បានមានប្រសាសន៍ថា សន្និបាតថ្ងៃនេះជាឱកាសដ៏មានសារៈសំខាន់សម្រាប់សមាជិកសមាគម ជាពិសេសប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ដើម្បីពិនិត្យឡើងវិញនូវលទ្ធផលការងាររបស់សមាគមដែលសម្រេចបានក្នុងឆ្នាំ២០២២ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៣ ហើយនេះក៏ជាវេទិកាជួបជុំគ្នាមួយ ដើម្បីពង្រឹងទំនាក់ទំនងរបស់សមាជិកសមាគម និងភាគីពាក់ព័ន្ធ រួមទាំងការចែករំលែកបទពិសោធន៍ការងារ ក៏ដូចជាព័ត៌មាន និងបច្ចេកវិទ្យាថ្មីៗពាក់ព័ន្ធនឹងវិស័យទឹកស្អាត។

**ឯកឧត្តម** បានសង្កត់ធ្ងន់ថា ក្រសួងឧវបន ទទួលស្គាល់ពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ បុគ្គលិក និងសមាជិកទាំងអស់ដែលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជានារយៈពេលកន្លងមក។ **ឯកឧត្តម** បានជម្រាបជូនអង្គសន្និបាតថា បច្ចុប្បន្នការផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជនទូទាំងប្រទេស អនុវត្តដោយរដ្ឋាករទឹកស្វយ័តចំនួន២ (រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងរដ្ឋាករទឹកស្វយ័តសៀមរាប) អង្គភាពរដ្ឋាករទឹកសាធារណៈចំនួន១០ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៣៥៤ទីតាំង ដែលទទួលបានប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតមានរយៈពេល២០ឆ្នាំពីក្រសួងឧវបន។ ចំនួនប្រតិបត្តិករបានកើនឡើង៥៣% ធៀបនឹងដើមឆ្នាំ២០១៨(ចំនួន ២៣១ប្រកាស)។ ព្រមជាមួយគ្នានោះដែរ **ឯកឧត្តម** បានបង្ហាញអំពីទិន្នន័យសំខាន់ៗដែលជាវឌ្ឍនភាពក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតតាមបំពង់នៅចន្លោះឆ្នាំ២០១៨ និងឆ្នាំ២០២២ផងដែរ ដូចខាងក្រោម៖

**១. បរិមាណផលិត និងផ្គត់ផ្គង់ទឹកស្អាត៖** កំណើន ២៨,៨៧% ដែលក្នុងនោះវិស័យឯកជនបានរួមចំណែកប្រមាណ ៣៤% នៃតួលេខផលិតកម្មសរុបក្នុងឆ្នាំ២០២២។
**២. ប្រវែងបណ្តាញផ្គត់ផ្គង់ទឹកស្អាត៖** កំណើន ៧៨,២០% ដែលក្នុងនោះវិស័យឯកជនបានរួមចំណែកប្រមាណ ៧៤% នៃប្រវែងបណ្តាញសរុបក្នុងឆ្នាំ២០២២។
**៣. ចំនួនតំណភ្ជាប់ជូនអតិថិជន៖** ក្នុងឆ្នាំ២០១៨ មានចំនួន ៧៨១,៩០៦តំណ និងកើនដល់ ១,២០៥,៧២៣តំណក្នុងឆ្នាំ២០២២ ពោលគឺកើនឡើង ៥៤,២០% ដែលក្នុងនោះវិស័យឯកជនបានរួមចំណែកប្រមាណ ៥២,៥០% នៃចំនួនតំណសរុបក្នុងឆ្នាំ២០២២។

**៤. ចំនួនភូមិសរុបក្នុងតំបន់សេវា (ដែលមានការអនុញ្ញាត)៖** ក្នុងឆ្នាំ២០២០ មានចំនួន ៥,៨៩២ភូមិ និងក្នុងឆ្នាំ២០២២ មានចំនួន ៨,៧៩៨ភូមិ ពោលគឺកើនឡើង ២,៩០៦ភូមិ ដែលស្មើនឹង ៤៩% ដែលក្នុងនោះវិស័យឯកជនបានរួមចំណែកប្រមាណ ៨១%។

**៥. ចំនួនភូមិដែលមានបណ្តាញទឹកស្អាតប្រើប្រាស់៖** ក្នុងឆ្នាំ២០២០ មានចំនួន ៤,២៥៧ ភូមិ និងក្នុងឆ្នាំ២០២២ មានចំនួន ៦,០៥៧ភូមិ ដែលស្មើនឹង ៤២% ធៀបនឹងចំនួនភូមិសរុបទូទាំងប្រទេស ១៤,៤០៥ភូមិ (ទិន្នន័យពីក្រសួងមហាផ្ទៃឆ្នាំ២០២១)។

**ឯកឧត្តម** បានបន្ថែមទៀតថា តាមរយៈតួលេខខាងលើបានបានឆ្លុះបញ្ចាំងពីតួនាទីយ៉ាងសំខាន់របស់វិស័យឯកជនក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ ជាពិសេសបានផ្តល់ទៅតំបន់ដែលសេវារដ្ឋទៅពុំដល់។ ក្រសួងពិនិត្យឃើញថា ការពង្រីកបណ្តាញរបស់ប្រតិបត្តិករ បានប្រមាណតែ ៦៦%ប៉ុណ្ណោះ បើធៀបទៅនឹងចំនួនភូមិសរុបដែលក្រសួងបានផ្តល់ប្រកាសអនុញ្ញាតជូន(ភូមិផ្តល់ប្រកាសជូនប្រតិបត្តិករឯកជនសរុបចំនួន ៧,១១៣ភូមិ ក្នុងនោះបានដាក់បណ្តាញរួចហើយចំនួន ៤,៧២៥ភូមិ)។

**ឯកឧត្តម** ក៏បានរំលឹកអំពីអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសគាំទ្រឱ្យប្រើពាក្យស្លោក «*ទឹកស្អាតសម្រាប់ទាំងអស់គ្នា*» កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ដោយក្នុងនោះប្រភពទឹកក៏នឹងត្រូវប្រើប្រាស់ «*ជាប្រភពពហុបំណង*»។ ក្នុងន័យនេះ ការអភិវឌ្ឍវិស័យទឹកស្អាត គឺជាការចាំបាច់ត្រូវការចូលរួមសហការអនុវត្តយ៉ាងសកម្មពីក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត អង្គភាពជំនាញ អាជ្ញាធរមូលដ្ឋាន វិស័យឯកជន និងប្រជាជនគ្រប់ជាន់ថ្នាក់ដែលមានការពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់ទឹកស្អាត **«ត្រឹមឆ្នាំ២០៣០ សម្រេចបាននូវការទទួលបានសាកលកម្ម និងសមធម៌នូវទឹកបរិភោគសម្រាប់ប្រជាជនទាំងអស់»**។

**ឯកឧត្តម** បានយកឱកាសនេះជម្រាបអំពី«សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត (Clean Water Management Law)» ដែលត្រូវបានគណៈរដ្ឋមន្ត្រីគាំទ្រ និងអនុម័ត និងបានបញ្ជូនទៅស្ថាប័ននីតិបញ្ញត្តិ ហើយបន្ទាប់មកទទួលបានការអនុម័តយល់ព្រមពីសភាជាតិរួចហើយកាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣។ តាមកម្មវិធីកំណត់នឹងដាក់ឆ្លងកិច្ចប្រជុំពេញអង្គវិសាមញ្ញរបស់ព្រឹទ្ធសភា នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣នេះផងដែរ។ ច្បាប់នេះមាន ១៥ជំពូក និង៦៦មាត្រា ដែលមានខ្លឹមសារគ្របដណ្តប់ទាំងលើទិដ្ឋភាពនយោបាយ គោលការណ៍ សមត្ថកិច្ច និងទិដ្ឋភាពបច្ចេកទេស រួមទាំងការលើកទឹកចិត្ត កាតព្វកិច្ច ការការពារចំពោះមុខច្បាប់ វិធានការគ្រប់គ្រង និងការទទួលខុសត្រូវតាមផ្លូវច្បាប់។ នេះជាច្បាប់ដំបូងបង្អស់សម្រាប់ប្រទេសកម្ពុជា លើការគ្រប់គ្រងទឹកស្អាត។ ច្បាប់នេះនឹងក្លាយជាឧបករណ៍គតិយុត្តមួយដែលគ្រប់គ្រង និងដោះស្រាយបញ្ហាប្រឈមរបស់ប្រតិបត្តិករ។ ជាឧទាហរណ៍៖ ក្នុងច្បាប់មានចែងពីការសងសំណងចំពោះការប៉ះពាល់បណ្តាញបំពង់ទឹកស្អាត ហើយបញ្ហាប្រភពទឹកក៏បានចែងក្នុងច្បាប់នេះផងដែរ។ ប្រភពទឹកមិនមែនជាបន្ទុកតែក្រសួងឧវបននោះទេ ប៉ុន្តែវាជាបន្ទុកសម្រាប់អ្នកពាក់ព័ន្ធជាច្រើនពី ៤

ថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។ គុណភាពទឹក គឺជាផ្នែកសំខាន់ក្នុងច្បាប់នេះផងដែរ សូមប្រតិបត្តិករទាំងអស់ចាប់ផ្តើមពង្រឹងគុណភាពទឹកបន្ថែមទៀត។ ច្បាប់ក៏មានការលើកទឹកចិត្តដល់ប្រតិបត្តិករក្នុងការការពារតំបន់សេវាកម្មរបស់ខ្លួន។ នៅពេលដែលច្បាប់នេះចូលជាធរមាន ក្រសួងនឹងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ តាមគ្រប់មធ្យោបាយ ហើយក្រសួងនឹងជូនការងារនេះឱ្យអគ្គនាយកដ្ឋានទឹកស្អាត ជាអ្នកដឹកនាំផ្សព្វផ្សាយ តាមរយៈសិក្ខាសាលា បណ្តាញសង្គម ធ្វើជាបទបង្ហាញ(ស្លាយ) វីដេអូ ជាដើម។

**ឯកឧត្តម** បានស្នើឱ្យអង្គសន្និបាតនេះ យកពេលវេលាដ៏មានតម្លៃមកធ្វើការផ្លាស់ប្តូរយោបល់ ផ្តល់ជាអនុសាសន៍ ឬគំនិតល្អៗ ដើម្បីញ៉ាំងឱ្យអ្នកចូលរួមនៅទីនេះអាចចាប់យកនូវចំណេះដឹង បទពិសោធន៍ បច្ចេកវិទ្យាថ្មីៗបន្ថែមទៀត ដើម្បីបន្តចូលរួមអភិវឌ្ឍន៍វិស័យទឹកស្អាតនៅប្រទេសកម្ពុជាឱ្យរីកលូតលាស់ល្អប្រសើរថែមទៀត។ ក្រសួងតែងតែអំពាវនាវដល់អ្នកពាក់ព័ន្ធដើម្បីជួយ៖

១. ពង្រឹង និងកែលម្អ ការផលិតទឹកស្អាតរបស់ប្រតិបត្តិករតាមរយៈការស្វែងរកបច្ចេកវិទ្យាថ្មីៗមកចែករំលែក។
២. ក្រុមហ៊ុនផ្គត់ផ្គង់សេវាបង់រំលស់សម្រាប់វិស័យទឹកស្អាតដើម្បីជួយដល់ប្រតិបត្តិករ
៣. សមាគមសូមចែករំលែកចំណេះដឹង បទពិសោធន៍ និងបច្ចេកវិទ្យាថ្មីៗដល់សមាជិក
៤. សូមឱ្យប្រតិបត្តិករចូលរួមគាំទ្រលើគោលនយោបាយជួយគ្រួសារក្រីក្រ (ការបង់រំលស់លើថ្លៃសេវាភ្ជាប់តំណរយៈពេល១០ឆ្នាំ) ក្រសួងកំពុងពិចារណាគិតគូរពីការចែងគោលការណ៍គាំទ្រដល់គ្រួសារក្រីក្រ។ តម្លៃទឹកពី 0-៣ម$^3$ក៏បានជួយដល់គ្រួសារក្រីក្របានមួយចំនួនរួចទៅហើយ។
៥. សូមអ្នកចូលរួមទាំងអស់ ចូលរួមឱ្យបានពេញលេញក្នុងសន្និបាតនេះ និងលើកយកបញ្ហាប្រឈមផ្សេងៗមកពិភាក្សាគ្នា។
៦. ក្រសួងនឹងរៀបចំការតាំងពិព័រណ៍ទិវាវិទ្យាសាស្ត្រ នៅកោះពេជ្រ ជាព្រឹត្តិការណ៍លើកទី១ ដែលនឹងប្រារព្ធនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣ ក្រោមអធិបតីរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដូច្នេះសូមសមាគមចូលរួមផ្សព្វផ្សាយបន្ត។

**ឯកឧត្តម** បានស្នើមកកាន់សមាគមឱ្យបង្កើននូវចំណងទាក់ទងអន្តរកម្មឱ្យកាន់តែជិតស្និទ្ធរវាងសមាជិកសមាគម សួរសុខទុក្ខ និងស្វែងយល់ពីគ្នាទៅវិញទៅមក ហើយសូមរក្សាប្រពៃណីនេះឱ្យបានជាប់ជាប្រចាំ។

ជាចុងក្រោយ **ឯកឧត្តម** បានជូនពរឱ្យអង្គសន្និបាតដំណើរការទៅដោយរលូន និងទទួលបានជោគជ័យតាមការរំពឹងទុក។

## ៤.២. សមិទ្ធិផលការងារក្នុងឆ្នាំ២០២២ និងផែនការប្រចាំឆ្នាំ២០២៣

**លោក លឹម មិញ** នាយកប្រតិបត្តិសមាគម បានធ្វើបទបង្ហាញពីសមិទ្ធិផលការងារឆ្នាំ២០២២ និងផែនការការងារឆ្នាំ២០២៣ ដូចខាងក្រោម៖

## ១. សមិទ្ធិផលការងារស្នូលសមាគមៈ

**ក. អភិបាលកិច្ចៈ** រៀបចំសន្និបាតលើកទី១០ ប្រចាំឆ្នាំ២០២២ សន្និសីទ និងពិព័រណ៍ទឹកកម្ពុជាលើកទី៤ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល (ប្រជុំប្រចាំត្រីមាសបានចំនួន ៣ត្រីមាស និងកិច្ចប្រជុំវិសាមញ្ញ បានចំនួន ១ដង)។

**ខ. ការងារជាមួយសមាជិកៈ** បច្ចុប្បន្នសមាគមមានសមាជិកសរុបចំនួន ៣២០ស្ថានីយ/ក្រុមហ៊ុន ដែលមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន ២៨៥ស្ថានីយ និងក្រុមហ៊ុនចំនួន ៣៥។ ក្នុងនោះដែរសមាគមបានរៀបចំកិច្ចប្រជុំតាមថ្នាក់តំបន់ បានចំនួន ១លើក។

**គ. ភាពជាតំណាងឱ្យសមាជិកៈ**

- សមាគមបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ និងប្រមូលធាតុចូលលើសេចក្តីព្រាងបបមបទដ្ឋានគតិយុត្តចំនួន ៤ ក្នុងក្របខណ្ឌគម្រោងកសាងសមត្ថភាពគ្រប់គ្រងវិស័យទឹកស្អាតកម្ពុជា។
- សមាគមបានចុះអនុស្សរណៈយោគយល់គ្នាចំនួន ៣ រួមមានៈ ១). អគ្គនាយកដ្ឋានទឹកស្អាត ក្រសួងឧវបន ២). ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា ម.ក និង ៣). សមាគមទឹកអូស្ត្រាលី(AWA)។
- កិច្ចប្រជុំដោះស្រាយបញ្ហារបស់សមាជិកបានចំនួន ២ដង។
- សមាគមបានសហការជាមួយមន្ទីរឧវបន និងសាខាពន្ធដារខេត្ត ក្នុងការបើកវគ្គបណ្តុះបណ្តាលស្តីពី«សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» បានចំនួន២វគ្គ និងបានសហការជាមួយក្រុមហ៊ុន TEM បើកវគ្គបណ្តុះបណ្តាលស្តីពី«ការសន្សំសំចៃថាមពលអគ្គិសនី» ១វគ្គ។
- សមាគមបានសម្របសម្រួលក្នុងការរៀបចំសិក្ខាសាលាតាមប្រព័ន្ធអនឡាញស្តីពីប្រព័ន្ធទឹកស្អាត និងអនាម័យ កម្ពុជាជប៉ុន- បានចំនួន ១វគ្គ។
- សមាគមបានសហការជាមួយ AWA, 3i និងក្រុមហ៊ុន WE Venture រៀបចំសិក្ខាសាលាស្តីពី«ការចែករំលែកចំណេះដឹងពីបច្ចេកវិទ្យា Ultra-Filtration និងលទ្ធផលនៃការសាកល្បងប្រើប្រាស់បច្ចេកវិទ្យាសម្អាតទឹកUltra-Filtration» បាន ១លើក។
- ក្រោមកិច្ចសហការរវាង AWA, 3i និង CWA បានរៀបចំវេទិកាពិភាក្សាស្តីពី គោលនយោបាយទឹក កម្ពុជា អូស្ត្រាលី លើកទី២ បាន ១វេទិកា។
- សមាគមបានរៀបចំដំណើរទស្សនកិច្ចសិក្សាជូនគណៈប្រតិភូអូស្ត្រាលីរួមមានៈ សមាគមទឹកអូស្ត្រាលី និងមន្ត្រីទូតរបស់អូស្ត្រាលី ទៅទស្សនកិច្ចនៅស្ថានីយទឹកស្អាតកំពង់ចំលង ស្ថានីយទឹកស្អាតឡេង ខៀវ ព្រែកអំបិល និងស្ថានីយទឹកស្អាតបែកចាន។
- សមាគមបានចូលរួមកិច្ចប្រជុំកំពូលស្តីពី«បច្ចេកវិទ្យា និងនវានុវត្តន៍ លើវិស័យទឹកស្អាតពិភពលោកឆ្នាំ២០២២» នៅទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស។
- សមាគមបានចូលរួមវេទិកាទឹកពិភពលោក World Water Forum ពីថ្ងៃទី២១-២៦ ខែមីនា ឆ្នាំ២០២២ នៅទីក្រុងដាកា ប្រទេស ហ្សេណេហ្គាល់។

- ❖ សមាគមបានដឹកនាំសមាជិករបស់ខ្លួនចំនួន ៨ស្ថានីយ ចូលរួមសន្និសីទទឹកអាស៊ី ឆ្នាំ២០២២ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។

២. **សមិទ្ធិផលការងារជាមួយដៃគូអភិវឌ្ឍន៍៖** ក្នុងឆ្នាំ២០២២នេះ សមាគមបានសហការអនុវត្ត គម្រោងជាមួយអង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មួយចំនួន រួមមាន៖

ក. គម្រោងគាំទ្រហិរញ្ញប្បទានលើការងារទឹកស្អាត និងអនាម័យ(WASH-FIN)

ខ. គម្រោងការពង្រឹងមូលដ្ឋានគ្រឹះសម្រាប់សន្តិសុខទឹក នៅកម្រិតស្រុក ក្នុងប្រទេសកម្ពុជា (WaterAid)

គ. គម្រោងការពង្រឹងគណនេយ្យភាពរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតដើម្បីលើកកម្ពស់ សេវាកម្មទឹកស្អាត (WaterAid)

ឃ. បង្កើនការទទួលសេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុសម្រាប់ជនងាយ រងគ្រោះនៅតាមសហគមន៍ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីផ្ទើមក្នុងវិស័យទឹកស្អាត និង អនាម័យប្រកបដោយបរិយាប័ន្ន (WaterAid)

ង. បង្កើននូវភាពធន់នឹងអាកាសធាតុសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតដល់ឃុំដែលមានហានិភ័យ ខ្ពស់ប្រឈមទៅនឹងបម្រែបម្រួលអាកាសធាតុ (UNICEF)

ច. គម្រោងសម្ព័ន្ធភាពដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌ (Aide et Action)

ឆ. គម្រោងឧបត្ថម្ភធនលើថ្លៃភ្ជាប់ទឹកជូនគ្រួសារក្រីក្រ (EMW)

ឈ. គម្រោងសិក្សារៀបចំព័ត៌មានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសម្រាប់រកទុនកម្ចី-Water.org

ជ. កម្មវិធីវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i)

៣. **របាយការណ៍ហិរញ្ញវត្ថុ៖** នៅក្នុងឆ្នាំ២០២២ សមាគមទទួលបានចំណូលសរុប និងចំណាយ សរុបដូចខាងក្រោម៖

**ក. ចំណូលសរុប៖** ៧៨១,០៣២ដុល្លារ ដែលក្នុងនោះមានថវិកាទទួលបានពី៖

- ❖ ដៃគូអភិវឌ្ឍន៍ និងម្ចាស់មូលនិធិសម្រាប់អនុវត្តគម្រោងកម្មវិធីទឹកស្អាតនានា៖ ៦៧៤,៧២៧ដុល្លារ ស្មើនឹង ៨៦%
- ❖ វិភាគទានសមាជិកភាពប្រចាំឆ្នាំ២០២១ និង២០២២៖ ៦០,៤៨៥ដុល្លារ ស្មើនឹង ៨%
- ❖ ចំណូលផ្សេងៗ៖ ៤៥,៨២០ដុល្លារ ស្មើនឹង៦%

**ខ. ចំណាយសរុប៖** សមាគមបានចំណាយលើប្រតិបត្តិការការងារចំនួន ៦៣៤,៩០៧ដុល្លារ

- ❖ ចំណាយលើការងារអភិវឌ្ឍន៍៖ ៤៣,៩០៣៥ដុល្លារ, ស្មើនឹង ៦៩%
- ❖ ចំណាយលើបុគ្គលិក៖ ១៦០៤៤៣ដុល្លារ, ស្មើនឹង២៥%
- ❖ ចំណាយលើកិច្ចប្រជុំបុគ្គលិក ក្រុមប្រឹក្សាភិបាល និងរដ្ឋបាល៖ ៣៥,៤២៩ដុល្លារ ស្មើនឹង ៦%។

**គ. សមតុល្យយោងសរុបទៅឆ្នាំបន្ទាប់៖** ១៤៦,១២៥ដុល្លារ។

៤. **ផែនការសកម្មភាព ២០២៣៖** ក្នុងឆ្នាំ២០២៣ សមាគមបានរៀបចំផែនការសកម្មភាពរបស់ ខ្លួនដោយផ្តោតលើការងារសំខាន់ៗដូចជា៖ ១.ការងារអភិបាលកិច្ច ២.ការងារកសាងសមត្ថ ភាពសមាជិក ៣.ការងារគាំពារសមាជិក ៤.ការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ កិច្ចប្រជុំ

តាមតំបន់ ៥.ការកសាងទំនាក់ទំនងសមាជិក ៦.កិច្ចសហការជាមួយដៃគូ ៧.ការងារអនុវត្តគម្រោងជាមួយដៃគូអភិវឌ្ឍន៍។

## ៤.៣ ការផ្តល់វត្ថុអនុស្សាវរីយ៍ជូនគណៈអធិបតី និងក្រុមប្រឹក្សាភិបាល

ដើម្បីអបអរសាទរសមិទ្ធិផលក្នុងឆ្នាំ២០២២ និងការសហការល្អ សមាគមបានរៀបចំជាវត្ថុអនុស្សាវរីយ៍ជូនដល់គណៈអធិបតីរួមមាន៖ ថ្នាក់ដឹកនាំក្រសួងឧវបន តំណាងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមប្រឹក្សាភិបាលទាំង ៩រូបផងដែរ។

បន្ទាប់មកគណៈអធិបតី និងអ្នកចូលរួមទាំងអស់បានថតរូបអនុស្សាវរីយ៍ និងបានទស្សនាតាមស្តង់ពិព័រណ៍របស់ក្រុមហ៊ុនទាំង ១៣ ដែលបានដាក់តាំងបង្ហាញនូវផលិតផល និងសេវាកម្មរបស់ខ្លួន។

## ៤.៤ បទបង្ហាញពីកម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលី ជាដៃគូសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED)

**លោក ហន ភារម្យ** តំណាងកម្មវិធីCAPRED បានធ្វើបទបង្ហាញពីកម្មវិធីភាពជាដៃគូកម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយភាពធន (CAPRED)។ បទបង្ហាញអំពីគោលដៅ និងគោលបំណង ផែនការចម្បងៗ សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម សេវាហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពសម្រាប់វិស័យទឹកស្អាតតាមបំពង់។

## ៤.៥ បទបង្ហាញពីកម្មវិធីហិរញ្ញប្បទានសម្រាប់ប្រតិបត្តិករទឹកស្អាត

**លោក ឡាយ ប៊ុនគ្រី** អ្នកសម្របសម្រួលអាជីវកម្មខ្នាតតូច និងមធ្យមគម្រោងទឹកស្អាតនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចម្រើន ម.ក ធ្វើបទបង្ហាញពីសាវតារ គម្រោងទឹកស្អាត និងអនាម័យ និងឥណទានប្រតិបត្តិករទឹកស្អាត។

## ៤.៦ បទបង្ហាញពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន

ការធ្វើបទបង្ហាញពីបច្ចេកវិទ្យាថ្មី ឬផលិតផលថ្មីៗរបស់ក្រុមហ៊ុនដែលបានចូលរួមគាំទ្រឧបត្ថម្ភ ដល់ការរៀបចំអង្គសន្និបាត ដែលក្នុងនោះមានក្រុមហ៊ុនចំនួន ៨ដូចខាងក្រោម៖

**ពេលព្រឹក៖**

1. Stone Family Foundation៖ មានកម្ចី និងការធ្វើទីផ្សារ
2. PETRAM Design Co., Ltd ៖ សេវាកម្ម គូរប្លង់អាងប្រព្រឹត្តិកម្មទឹកស្អាត និងសំណង់ផ្សេងៗ
3. ក្រុមហ៊ុនវ៉េជីម៉ិច ថេកណូឡជី៖ មានផ្គត់ផ្គង់សម្ភារៈទឹកស្អាត

**ពេលរសៀល៖**

4. ក្រុមហ៊ុន Rose Plastic Cambodia៖ មានផ្គត់ផ្គង់បំពង់ HDPE និងគ្រឿងតំណ
5. ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា FTB៖ ផ្តល់កម្ចីសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត (កម្ចីសម្រាប់សហគ្រាសខ្នាតមធ្យម និងខ្នាតតូច (SME) និងសាជីវកម្មជានាឥណទានកម្ពុជា)

6. ក្រុមហ៊ុន **ដៃគូទឹកកម្ពុជា ( Water Partner Cambodia )៖** មានផ្គត់ផ្គង់សារធាតុគីមី គ្រឿងតំណ នាឡិកាទឹក បំពង់ទឹកស្អាត វ៉ាន ម៉ូទ័របូមទឹក ប្រព័ន្ធគ្រប់គ្រងទឹកវៃឆ្លាត (បញ្ជាម៉ូទ័រស្វ័យប្រវត្តិ វាស់គុណភាពទឹក វាស់សម្ពាធទឹក...)
7. **ក្រុមហ៊ុន HTS៖** មានផ្គត់ផ្គង់បំពង់ទឹកស្អាត HDPE និងបង្ហាញអំពីរបៀបមើលគុណភាពទុយោ ម៉ាស៊ីនអ៊ុតទុយោ និងគ្រឿងតំណផ្សេងៗប្រឹក្សាយោបល់លើផ្នែកបច្ចេកទេស
8. ក្រុមហ៊ុន **TEM Trading Co., Ltd៖** មានផ្គត់ផ្គង់ទូបញ្ជា ម៉ូទ័របូមទឹក វ៉ាន នាឡិកាទឹក ប្រព័ន្ធសូឡា។ល។

## ៤.៥ បច្ចុប្បន្នភាពអំពី«សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត»

**លោក ឿន ប៊ុនហេង** តំណាងក្រុមហ៊ុន រ៉ូចន៍ & ផាតនើរ បានឡើងធ្វើបទបង្ហាញស្តីពី«សិទ្ធិ និងកាតព្វកិច្ច របស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» ដែលមានខ្លឹមសារសំខាន់ៗដូចខាងក្រោម៖

- ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
- ប្រភេទពន្ធដែលត្រូវបង់ (ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម ពន្ធលើប្រាក់រំដោះប្រាក់ចំណូល)។
- ទោសទណ្ឌចំពោះការមិនបំពេញកាតព្វកិច្ចសារពើពន្ធ។

## ៤.៦ ការចែករំលែកបទពិសោធន៍ពីទស្សនកិច្ចសិក្សានៅក្រៅប្រទេស

- **អ្នកស្រី ព្រាប បុទុមសិលា** អ្នកគ្រប់គ្រងស្ថានីយផ្គត់ផ្គង់ទឹកស្អាតសំរោងយ៉ោង បានចែករំលែកពីការចូលរួមក្នុងសន្និសីទទឹកអាស៊ី នៅប្រទេសម៉ាឡេស៊ី។
- អ្នកស្រី **ស៊ីម សៀមនី** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំការលើ បានចែករំលែកពីការចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធទឹកស្អាតជប៉ុន នៅប្រទេសជប៉ុន។

## ៤.៨ សំឡេងសមាជិកភាព និងដំណោះស្រាយ

**លោក លឹម មិញ** បានសម្របសម្រួលឱ្យមានវេទិកា សំណួរ ចម្លើយ និងសំណូមរបស់សមាជិក។

| សំណួរ យោបល់ផ្សេងៗរបស់សមាជិក | ការឆ្លើយតប |
|---|---|
| 1. **លោក យឹម សំអឿន** នាយកប្រតិបត្តិនៃក្រុមហ៊ុនលង្វែក បានលើកពីបញ្ហាជាន់តំបន់អាជ្ញាបណ្ណគ្នាចំនួន៣ឃុំ (ឃុំវិហារហ្លួង ឃុំផ្សារដែក និងឃុំភ្នំបាត)។ បច្ចុប្បន្នក្រុមហ៊ុនបានរាយបណ្តាញទុយោទឹកចូលក្នុងតំបន់ដែលជាន់គ្នាហើយ។ ដូច្នេះក្រុមហ៊ុនស្នើសុំក្រសួងឧវបន ជួយដោះស្រាយផង។ | **បញ្ហាជាន់តំបន់អាជ្ញាបណ្ណ៖**<br>1. **លោក សៀ សេងហ៊ាប** ហេរញ្ញិកនៃក្រុមប្រឹក្សាភិបាលសមាគម បានចូលរួមថា សមាគមនឹងធ្វើការដោះស្រាយបញ្ហារបស់សមាជិក ដោយស្នើឱ្យម្ចាស់ស្ថានីយអញ្ជើញមក សមាគមដើម្បីពិភាក្សាស្វែងយល់ពីបញ្ហា និងដាក់លិខិតមកកាន់ |

8

| សំណួរ យោបល់ផ្សេងៗរបស់សមាជិក | ការឆ្លើយតប |
|---|---|
| 2. **លោក ប៉ែន សាវ៉ាន់** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតព្រែករាំង បានលើកបញ្ហាខូចខាតបណ្ដាញទឹកស្អាត ដោយសារការស្ថាបនាផ្លូវថ្នល់។ ខាងមន្ទីរសាធារណៈការ និងដឹកជញ្ជូន ខេត្តកំពង់ឆ្នាំង បានលើកឡើងថា ខាងប្រតិបត្តិករទឹកស្អាតដាក់បំពង់ទឹកស្អាតមិនតាមស្តង់ដា(កប់ក្នុងដីចំណីផ្លូវឬ ប្រឡាយ)។ ប៉ុន្តែ **លោក សាវ៉ាន់** ក៏បានសួរសំណួរវិញថា តើប្រតិបត្តិករអាចកប់បំពង់ទឹកស្អាតកាត់ផ្ទះរបស់ប្រជាពលរដ្ឋបានដែរឬទេ? បើស្ថានភាពសំណង់របស់ប្រជាពលរដ្ឋស្ថិតនៅតាមចំណីផ្លូវដូច្នេះ។<br>3. **លោក សុផល** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតជាលា បានលើកពីបញ្ហាជាន់តំបន់អាជ្ញាបណ្ណ និងការផ្លាស់ប្តូរការទទួលខុសត្រូវលើតំបន់អាជ្ញាបណ្ណ តើមានការកាត់កងលើថ្លៃវិនិយោគ និងកាតព្វកិច្ចពន្ធដារយ៉ាងដូចម្ដេច?<br>4. **លោក អំណាត់ វីរីយ៉ា** តំណាងក្រុមហ៊ុន យុន អភិវឌ្ឍន៍ បានចែករំលែកអំពីបទពិសោធន៍ក្នុងការដោះស្រាយលើបញ្ហាខូចខាតបណ្ដាញបំពង់ទឹកស្អាតដូចខាងក្រោម៖<br>- ក្រុមហ៊ុនធ្លាប់ខូចខាតបំពង់ជាង៦០ គីឡូម៉ែត្រពីការសាងសង់ផ្លូវជាតិលេខ៥<br>- ក្រុមហ៊ុនបានចចារជាមួយ JICA និងប្តឹងពីថ្នាក់ក្រោមជាតិរហូតដល់ថ្នាក់ជាតិ ដើម្បីសម្របសម្រួល។ ក្រោយមកមានចេញជា ស.ជ.ណា មួយដើម្បីជួយសម្រាលពីការខូចខាតបំពង់ទឹកស្អាត។<br>- ដោយសារខូចខាតច្រើនពេក ក្រុមហ៊ុនបានស្នើសុំការចូលរួមបដិភាគពីប្រជាពលរដ្ឋ តែក្រោយមកខាងគណៈគ្រប់គ្រងការងារបក្សប្រចាំតំបន់នោះបានជួយចេញប្រាក់ជំនួសប្រជាពលរដ្ឋ<br>- លោកក៏បានសួរសំណួរអំពីមានច្បាប់ណាដែលមិនឱ្យក្រុមហ៊ុនជីកអណ្តូងទឹកដើម្បីធ្វើជាប្រភពទឹកដែរឬទេ? ព្រោះ | សមាគម រួចសមាគមនឹងចូលរួមដោះស្រាយ។<br>2. **អ្នកស្រី យ៉ាន ធីតា** សមាជិកក្រុមប្រឹក្សាភិបាល បានចែករំលែកអំពីបទពិសោធន៍ក្នុងការដោះស្រាយវិវាទ ដោយប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់ បន្ទាប់មកជួប និងដាក់ពាក្យបណ្ដឹងទៅកាន់មន្ទីរឧស្សាហកម្ម... <br><br>**បញ្ហាខូចខាតបំពង់ទឹកស្អាត៖**<br>1. **លោក ហៀក អេងឡាយ** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំចាយមារ បានលើកពីដំណោះស្រាយអំពីសំណងនៃការខូចខាតបំពង់ទឹកស្អាតពីការអភិវឌ្ឍន៍ផ្លូវថ្នល់ ក្រុមប្រឹក្សាភិបាលមិនមានចម្លើយនោះទេ ព្រោះវាជាការអភិវឌ្ឍន៍ ហើយក្រុមប្រឹក្សាភិបាលក៏រងផលប៉ះពាល់ផងដែរ។ ប៉ុន្តែសមាគមនឹងខិតខំពាំនាំយកបញ្ហានេះមកពិភាក្សាជាមួយអ្នកពាក់ព័ន្ធដើម្បីរកដំណោះស្រាយ។ លោកក៏បានផ្តល់យោបល់ដល់ប្រតិបត្តិករដើម្បីការពារកុំឱ្យមានការជាន់តំបន់គ្នា ប្រតិបត្តិករគួតែដាក់បង្គោលចំណាំនៅតាមព្រំប្រទល់ភូមិទាំងអស់ដែលទល់នឹងតំបន់សេវាកម្មរបស់ប្រតិបត្តិករផ្សេងទៀត។<br>2. **អ្នកស្រី យ៉ាន ធីតា** សមាជិកក្រុមប្រឹក្សាភិបាល បានស្នើឱ្យប្រតិបត្តិករ៖<br>- មានការប្រុងប្រយ័ត្នពេលកប់បណ្ដាញបំពង់ទឹកស្អាត ដោយកប់ឱ្យបានត្រឹមត្រូវតាមបច្ចេកទេស ។ |

| សំណួរ យោបល់ផ្សេងៗរបស់សមាជិក | ការឆ្លើយតប |
|---|---|
| ប្រជាជនតំបន់នោះមិនអនុញ្ញាតឱ្យក្រុមហ៊ុនជីកទេដោយសារខ្លាចស្រុតដី និងផ្ទះរបស់គាត់។<br>5. **លោក សុត សឿន** ម្ចាស់ស្ថានីយទឹកស្អាត សុត សឿន ខេត្តពោធិ៍សាត់ បានលើកឡើងពីបញ្ហាលំបាកអំពីការចាក់ដីបន្ថែមរបស់ប្រជាពលរដ្ឋ ធ្វើឱ្យស្ថានីយពិបាកស្វែងរកបណ្តាញបំពង់ទឹកស្អាត។ លោកក៏បានលើកពីបញ្ហាជាន់តំបន់សេវាកម្ម ដោយសារខាងរដ្ឋបាលខេត្តបានជំរុញឱ្យគាត់វាយបណ្តាញទឹកស្អាតចូលតំបន់មួយ តែក្រោយមកបែរជាក្រសួងឧវបន គ្រោងចេញប្រកាសអនុញ្ញាត ២០ឆ្នាំជូនក្រុមហ៊ុនមួយផ្សេងទៀត។<br>6. **លោក ទូច សារ៉េន** ម្ចាស់បណ្តាញចែកចាយទឹកស្អាត ទូច សារ៉េន ខេត្តក្រចេះ បានលើកអំពីការជាន់អាជ្ញាបណ្ណមួយភូមិជាមួយក្រុមហ៊ុនទឹកស្អាតក្រុងក្រចេះ។ បញ្ហានេះបានកើតឡើងជាយូរមកហើយ តែនៅមិនទាន់មានដំណោះស្រាយសោះ។ លោកសំណូមពរឱ្យក្រសួង និងសមាគមជួយដោះស្រាយផង។<br>7. **លោក ផុន សុគន្ធ** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្បែងខ្ពស់ បានចែករំលែកបទពិសោធន៍អំពីការដោះស្រាយពេលមានការអភិវឌ្ឍន៍ផ្លូវថ្នល់៖<br>- ប្រតបត្តិករគួរចូលរួមជាមួយអាជ្ញាធរមូលដ្ឋានក្នុងការសិក្សាពីផលប៉ះពាល់ដោយសារការសាងសង់ផ្លូវ លូរ និងដាក់ផែនការជាមុនដើម្បីចៀសវាងការខូចខាតទុយោ<br>- ប្រតិបត្តិករគួរចូលរួមសហការលើកបំពង់ទឹកស្អាតក្នុងកំឡុងពេលនៃការសាងសង់ផ្លូវថ្នល់<br>- ម៉្យាងវិញទៀត សមាជិកជាប្រតិបត្តិករមួយចំនួនមិនសូវមានភាពសាមគ្គីគ្នាក្នុងការដោះស្រាយបញ្ហារួមនោះទេ។<br>ឧ. ពេលអញ្ជើញមកប្រជុំអំពីបញ្ហាខូច | - កប់បំពង់ទឹកស្អាតដោយមើលព្រំបង្គោលភ្លើង<br>- កាយកប់កាត់ផ្ទះប្រជាជនត្រូវមានការចរចាជាមួយពួកគាត់ និងមានការជួសជុលឱ្យពួកគាត់វិញ។<br>3. **លោក សៀវ ហួត** សមាជិកក្រុមប្រឹក្សាភិបាល បានចែករំលែកបទពិសោធន៍៖<br>- បច្ចុប្បន្នប្រតិបត្តិករពុំដឹងថាគួរធ្វើយ៉ាងណាដើម្បីកប់បំពង់ទឹកស្អាតឱ្យត្រូវនោះទេ ព្រោះប្រជាជនសាងសង់ផ្ទះរំលោភចំណីផ្លូវ<br>- ស្ថានីយរបស់លោកក៏ជួបផលលំបាកដែរ លោកបានដាក់ពាក្យបណ្តឹងពីថ្នាក់ភូមិ/ឃុំ/ស្រុក ទៅដល់ខេត្ត/ក្រសួង។ ជាលទ្ធផលពេលមានការសាងសង់ផ្លូវមន្ទីរតែងជូនដំណឹងជាមុន។ លោកក៏បានស្នើឱ្យប្រតិបត្តិករត្រូវធ្វើការជាមួយរដ្ឋបាលស្រុកដើម្បីពិភាក្សាអំពីការបញ្ចៀសផលប៉ះពាល់ ដោយមានការសម្របសម្រួលជាមួយអ្នកម៉ៅការសាងសង់។<br>4. **លោក ហាម ងួន** អនុប្រធានក្រុមប្រឹក្សាភិបាល បានបង្ហាញថា ស្ថានីយរបស់លោកក៏ជួបផលប៉ះពាល់ធ្ងន់ធ្ងរពីការស្ថាបនាផ្លូវថ្នល់ដែរ។ ដូច្នេះលោកស្នើឱ្យមានការយោគយល់ពីខាងពន្ធដារ ដើម្បីលើកលែងលើពន្ធខ្លះចំពោះវិស័យទឹកស្អាតតាមបំពង់។<br>5. **លោក ឡេង ខៀវ** ប្រធាន ក្រុមប្រឹក្សាភិបាល បានស្នើឱ្យសមាជិកទាំងអស់សហការគ្នាឱ្យបានរឹងមាំដើម្បីដោះស្រាយបញ្ហាប្រឈមរួមគ្នា។ ក្រសួងក៏បានគាំទ្រ និងសហការល្អជាមួយសមាគមកន្លងមក និងបានដោះស្រាយបញ្ហាមួយចំនួនកន្លងមកដែរ។ ម៉្យាងទៀត សេចក្តីព្រាងច្បាប់គ្រប់គ្រងទឹកស្អាតក៏ជាសមិទ្ធផលពីការរួមចំណែករបស់សមាគម ដែលនឹងអាចជួយ |

| សំណួរ យោបល់ផ្សេងៗរបស់សមាជិក | ការឆ្លើយតប |
|---|---|
| ខាតបំពង់ទឹកស្អាតក្នុងខេត្ត មាន ប្រតិបត្តិករមួយចំនួនអវត្តមាន ធ្វើឱ្យ កម្លាំងតស៊ូមតិមានការថយចុះ។ សូមឱ្យ សមាជិកទាំងអស់រួមសាមគ្គី និងសកម្ម ទាំងអស់គ្នា។<br>8. **លោក ព្រំចន្ថា** ម្ចាស់ស្ថានីយទឹកស្អាត អូរតាតន់ ស្រុកមោងឫស្សី ខេត្តបាត់ដំបង បាន លើកពីបញ្ហាខូចខាតបំពង់ទុយោច្រើន អាច មាន ៤០ករណីក្នុង១ថ្ងៃ។ លោកស្នើសុំ សមាគមធ្វើការផ្សព្វផ្សាយអំពីការចូលរួម ថែទាំបណ្តាញទឹកស្អាត និងស្នើសុំឱ្យខាង ពន្ធដារ ជួយលើកលែងរយៈពេលនៃការបង់ ពន្ធដល់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។ | ដោះស្រាយបញ្ហារបស់បងប្អូនប្រតិបត្តិករ ផងដែរ។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានជ្រាបពីបញ្ហាប្រឈម ចំពោះវិស័យផ្គត់ផ្គង់ទឹកស្អាតនេះដែរ។<br>**បញ្ហាខួងអណ្តូង៖**<br>1. លោក **ហៀក អេងឡាយ** សមាជិកក្រុម ប្រឹក្សាភិបាល បានចែករំលែកបទពិសោធន៍ ថា បើជីកអណ្តូងចម្ងាយពីភូមិ ៣០០ម៉ែត្រ ក្រុមហ៊ុនអាចជីកអណ្តូងបានហើយ។ លោកក៏បានផ្តល់យោបល់ថា ប្រតិបត្តិករ ដែលគ្រោងខួងអណ្តូងគួរតែសិក្សាលក្ខណៈ បច្ចេកទេស និងពិភាក្សាជាមួយមន្ទីរអភិវឌ្ឍន៍ ជនបទអំពីផលប៉ះពាល់ដែលបណ្តាលឱ្យ ស្រុតដី ឬផ្ទះប្រជានរដ្ឋនៅក្បែរនោះដែរ ឬ ទេ។ |

## ៤.៩ ពិភាក្សាលើប្រាក់វិភាគទានសមាជិកភាពប្រចាំ

កញ្ញា **ខាត់ ដាវី** អ្នកសម្របសម្រួលសមាជិកភាពសមាគម បានធ្វើបទបង្ហាញអំពីការស្នើសុំបន្ថែមប្រាក់វិភាគទានសមាជិកភាពប្រចាំឆ្នាំ ចាប់ពីឆ្នាំ២០២៣តទៅ។

លោក **លឹម មិញ** ក៏បានបង្ហាញអំពីមូលហេតុនៃការស្នើសុំបង្កើនប្រាក់វិភាគទានសមាជិកភាពដូចខាងក្រោម៖

- អនុវត្តការងារស្នូលរបស់សមាគមឱ្យបានច្រើនជាងមុន
- សមាគមគ្រោងនឹងរើសបុគ្គលិកបន្ថែមដើម្បីធ្វើការងារជាមួយសមាជិក ដែលតម្រូវការថវិកាបន្ថែម។
- ចូលរួមចំណាយទៅលើថ្លៃប្រតិបត្តិការរបស់សមាគម

ក្រោយពីបទបង្ហាញ និងការបកស្រាយរួចមក សមាជិកដែលចូលរួមទាំងអស់មិនមានការជំទាស់លើការស្នើសុំដំឡើងប្រាក់វិភាគទានសមាជិកនេះទេ។

**ក្រុមប្រឹក្សាភិបាលបានសម្រេចកែសម្រួលប្រាក់វិភាគទានសមា ជិកភាពប្រចាំឆ្នាំ**

| ប្រភេទសមាជិ | ចំនួនតំណប្រភេទ | ប្រាក់វិភាគទានប្រឆ្នាំ | ប្រាក់វិភាគទានប្រចាំថ្មី |
|---|---|---|---|
| សមាជិកអចិព | 0-750 | **130ដុល្លារ** | 200ដុល្លារ |
| | 751-1500 | **180ដុល្លារ** | 250ដុល្លារ |
| | 1501-3000 | **300ដុល្លារ** | 350ដុល្លារ |
| | 3001-6000 | **500ដុល្លារ** | 500ដុល្លារ |
| | 6001ឡើងទៅ | | 700ដុល្លារ |
| សមាជិកគាំទ្រ | រូបវន្តបុគ្គល | ៥០ដុល្លារ | |
| | និតីបុគ្គលខ្មែរ | ២០០ដុល្លារ | ២៥០ដុល្លារ |
| | និតីបុគ្គលបរទេស | ៣០០ដុល្លារ | ៣៥០ដុល្លារ |

## ៤.១០ សុន្ទរកថាបិទសន្និបាតលើទី១១

ក្នុងកម្មវិធីបិទអង្គសន្និបាត **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម បាន ថ្លែងសុន្ទរកថាបិទកម្មវិធី ដោយលើកឡើងថា អង្គសន្និបាតលើកទី១១ នេះរៀបចំ និងទទួលបានលទ្ធផលជោគជ័យគួរជាទីមោទនភាព និងបង្ហាញអំពីចំណងសាមគ្គីភាពក្នុងស្មារតីជាក្រុមគ្រួសាររបស់អ្នកផ្គត់ផ្គង់ទឹកស្អាត។ យើងមានកិច្ចការច្រើនដែលត្រូវធ្វើបន្តទៀត ប៉ុន្តែជារបត់ថ្មីដែលយើងបានចូលរួមអបអរសាទរ គឺការផ្គត់ផ្គង់ទឹកស្អាត ស្ថិតក្នុងក្របខណ្ឌច្បាប់មួយច្បាស់លាស់ វាជាជំហាននៃការពង្រឹងប្រសិទ្ធភាព ពង្រឹងគុណភាពទឹកស្អាត និងអភិវឌ្ឍន៍វិស័យផ្គត់ផ្គង់ទឹកស្អាតដើម្បីសម្រេចបាននូវចក្ខុវិស័យសម្រាប់រយៈពេលវែង។ ច្បាប់នេះទទួលបានការគាំទ្រទាំងស្រុងពីអង្គនីតិបញ្ញត្តិ។ ក្នុងឱកាសបិទនេះផងដែរ **ឯកឧត្តម** បានចូលរួមបកស្រាយចំណុចមួយចំនួនដែលបានលើកឡើងដោយសមាជិកសមាគមថា បញ្ហាដែលបានលើកភាគច្រើនផ្តោតលើការត្រួតស៊ីគ្នានៃតំបន់អាជ្ញាបណ្ណ និងការខូចខាតបណ្តាញបំពង់ទឹកស្អាត ដើម្បីដោះស្រាយបញ្ហាទាំងនេះយើងត្រូវមានគោលការណ៍ និងច្បាប់ច្បាស់លាស់ក្នុងការដោះស្រាយ។ ជាឧទាហរណ៍៖ នៅក្នុងមាត្រា២៣ និង២៤ បានបង្ហាញអំពីលក្ខខណ្ឌនៃការដាក់បណ្តាញបំពង់ទឹកស្អាតរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងកិច្ចសហការនានា ដែលជាទម្ងន់មួយដែលអាចជួយដល់ប្រតិបត្តិករផងដែរ។ ចំពោះមាត្រា៥១ បានបង្ហាញអំពីពិន័យអន្តរកាលនៃការធ្វើឱ្យប៉ះពាល់ដល់បណ្តាញបំពង់ទឹកស្អាត។ ចំពោះបញ្ហាជាន់អាជ្ញាបណ្ណ សូមធ្វើការដោះស្រាយត្រឹមក្របខណ្ឌសមាគមសិន មុននឹងបន្តជូនទៅកាន់ក្រសួង និងសូមឱ្យប្រតិបត្តិករប្រមូលភស្តុតាងឱ្យបានគ្រប់គ្រាន់ដើម្បីគាំទ្រដល់ដំណើរការនៃការដោះស្រាយ។ **ឯកឧត្តម** បានបន្ថែមថា ក្រសួងនឹងផ្តល់អាទិភាពផ្តល់អាជ្ញាបណ្ណតំបន់ថ្មីដល់ប្រតិបត្តិករដែលកំពុងប្រតិបត្តិការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ក្បែរៗគ្នាដែលមិនទាន់មានអាជ្ញាបណ្ណទាំងនោះដើម្បីចំណេញពេលវេលាក្នុងការសិក្សាសមិទ្ធិលទ្ធភាពម្តងទៀត។ ក៏ប៉ុន្តែប្រសិនបើ

ប្រតិបត្តិករណាដែលមិនទាន់បានពង្រីកបណ្តាញទុយោក្នុងតំបន់សេវាកម្មរបស់ខ្លួនឱ្យបាន ៨០% ទេនោះក្រសួងនឹងមិនផ្តល់អាជ្ញាបណ្ណដល់ប្រតិបត្តិករនោះឱ្យពង្រីកចូលតំបន់ថ្មីដែលនៅក្បែរៗនោះឡើយ។

**ឯកឧត្តម** សូមគាំទ្រដល់ការសាមគ្គីភាពរបស់សមាជិកក្នុងការដោះស្រាយបញ្ហារួមគ្នា ដូច្នេះប្រតិបត្តិករត្រូវចូលជាសមាជិកសមាគម ដើម្បីឱ្យសមាគមមានកម្លាំង និងមានសំឡេងក្នុងការដោះស្រាយបញ្ហារបស់សមាជិក។

ជាចុងក្រោយ **ឯកឧត្តម** បានលើកជាអនុសាសន៍ណែនាំមួយចំនួនដូចខាងក្រោម៖

- សូមឱ្យប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតទាំងអស់គោរពច្បាប់ទាំងអស់គ្នា
- សូមគិតដល់ប្រយោជន៍សាធារណៈ ត្រូវបញ្ជ្រាបការយល់ដឹងអំពីច្បាប់ទឹកដល់អ្នកពាក់ព័ន្ធទាំងអស់
- ចំពោះបញ្ហាពន្ធដារ យើងត្រូវរកហេតុផលច្បាស់លាស់អំពីការស្នើសុំលើកលែងពន្ធនេះ
- ចំពោះការជួយដល់គ្រួសារក្រីក្រឱ្យទទួលបានសេវាទឹកស្អាតប្រើប្រាស់ ក្រសួងកំពុងតែគិតគូរតាក់តែគោលការណ៍នេះ
- សមាគមត្រូវពង្រឹងភាពជាដៃគូឱ្យបានកាន់តែខ្លាំងក្លាជាមួយក្រសួង ដើម្បីអភិវឌ្ឍវិស័យទឹកស្អាតនៅកម្ពុជា ម្យ៉ាងវិញទៀត ឈ្មោះសមាគម និងតួនាទីរបស់សមាគម ក៏មានចែងក្នុងច្បាប់ទឹកនេះផងដែរ
- ចំពោះមូលនិធិអភិវឌ្ឍន៍ទឹកស្អាតនឹងជួយគាំទ្រទៅដល់គ្រួសារក្រីក្រឱ្យទទួលបានទឹកស្អាតប្រើប្រាស់ និងគាំទ្រដល់ប្រតិបត្តិករណាដែលខ្សត់ខ្សោយដើមទុនក្នុងការពង្រីកសេវាកម្ម
- សមាគម និងសមាជិកទាំងអស់ត្រូវចូលរួមឱ្យបានពេញលេញក្នុងការអនុវត្តច្បាប់នាពេលខាងមុខ។

សន្និបាតលើកទី១១ របស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ត្រូវបានបញ្ចប់នៅវេលាម៉ោង ៥ល្ងាច នៅក្នុងថ្ងៃខែឆ្នាំដដែល ប្រកបដោយភាពជោគជ័យ សប្បាយរីករាយ និងស្និទ្ធស្នាលជាទីបំផុត។

ថ្ងៃសុក្រ ១២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣

**អ្នកធ្វើកំណត់ហេតុ**

**តូច សុគន្ធា**

**បានឃើញ និងឯកភាព**

**ប្រធាន**

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
ស.ព.ក
C.W.A
Cambodian Water Supply Association

**ឡេង ខៀវ**